ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ

២-មេធាវី អ៊ឹង គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៊ុលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកនួន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈឹម តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មាននួ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី យឹម វិស្សុត

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហួរ

២៣-មេធាវី ទ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ: ០៥៩ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្តីសម្រេចលេខ ២២៨/សសគម/១៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ របស់គណៈមេធាវី ស្តីពីការអនុញ្ញាតឱ្យលោក **ម៉ម ស៊ីដាណា** ចូលប្រកបវិជ្ជាជីវៈមេធាវី
- បានឃើញកំណត់ហេតុសច្ចាប្រណិធានលេខ ០៩/២០១៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍
- យោងតាមសំណើរបស់សាមីខ្លួន
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ។


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨

ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

# សម្រេច

**ប្រការ ១.-** លោកមេធាវី **ម៉ម ស៊ីដាណា** អត្តលេខ **១១៧៦ T** ត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សារយៈពេល ១២(ដប់ពីរ)ខែ ជាមួយលោកមេធាវី **ពេជ្រ សុរិយា** នៅ **ក្រុមហ៊ុនមេធាវី ខ្មែរអប្សរា** ដែលមានអាសយដ្ឋានស្ថិតនៅ**ផ្ទះលេខ ៥អា ផ្លូវលេខ ២៨៥ សង្កាត់បឹងកក់ទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះតទៅ។

**ប្រការ ២.-**
- រាល់ទំនាក់ទំនង និងគ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។
- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។
- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច។

**ប្រការ ៣.-** កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនានារបស់គណៈមេធាវី និងចូលរួមគ្រប់សកម្មភាពដែលចាត់តាំងដោយគណៈមេធាវី។

**ប្រការ ៤.-** កម្មសិក្សាការីត្រូវមានកាតព្វកិច្ចជួយការពារក្ដីជូនជនក្រីក្រតាមការចាត់តាំងរបស់គណៈមេធាវី។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក គ្រូកម្មសិក្សា និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមមុខការរៀងៗខ្លួន៕

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

**មេធាវី. ប៊ុន-ហុន**

**ចម្លងជូនៈ**

-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ